# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តភ្នំពេញ

លេខ...០៧៥/១៩...ក. ស. ភ.

ថ្ងៃសុក្រ ៥កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព. ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩

## សេចក្តីជូនដំណឹង

## ស្តីពី

## ការកែសម្រួលតម្លៃសេវាកម្មនៅកំពង់ផែស្វយ័តភ្នំពេញ

**កំពង់ផែស្វយ័តភ្នំពេញ "ក. ស. ភ."** សូមជម្រាបជូនដំណឹង ដល់អតិថិជនទាំងអស់ មេត្តាជ្រាបថា ដើម្បីរួមចំណែកកាត់បន្ថយតម្លៃដឹកជញ្ជូន និងភស្តុភារកម្ម ក្នុងគោលដៅសម្រួលដល់ការធ្វើធុរៈកិច្ច និងការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា ក. ស. ភ. បានសម្រេចធ្វើការកែសម្រួលបញ្ចុះតម្លៃសេវាកម្មមួយចំនួន ដូចខាងក្រោម៖

១. <u>តម្លៃលើកដាក់ពីនាវាទៅទីលានស្តុកកុងតឺន័រ និងពីទីលានស្តុកកុងតឺន័រទៅនាវា (Stevedoring Charges)</u>

| ប្រភេទកុងតឺន័រ | តម្លៃបច្ចុប្បន្នក្នុង ១កុងតឺន័រ | តម្លៃអនុគ្រោះថ្មីក្នុង ១កុងតឺន័រ |
|---|---|---|
| កុងតឺន័រគ្មានទំនិញ ២០ហ្វីត | ៣៦ ដុល្លារអាមេរិក | ៣០ ដុល្លារអាមេរិក |
| កុងតឺន័រមានទំនិញ ២០ហ្វីត | ៦៥ ដុល្លារអាមេរិក | ៥៦ ដុល្លារអាមេរិក |
| កុងតឺន័រគ្មានទំនិញ ៤០ហ្វីត | ៥៣ ដុល្លារអាមេរិក | ៤៦ ដុល្លារអាមេរិក |
| កុងតឺន័រមានទំនិញ ៤០ហ្វីត | ៩៩ ដុល្លារអាមេរិក | ៨៥ ដុល្លារអាមេរិក |

*<u>បញ្ជាក់:</u>* តម្លៃខាងលើនេះពុំគិតរួមបញ្ចូលអាករលើតម្លៃបន្ថែម ១០% ទេ។

២. រយៈពេលនៃការលើកលែងថ្លៃស្តុកទុកកុងតឺន័រនៅលើទីលានសម្រាប់កុងតឺន័រនាំចេញ ត្រូវបានបន្ថែមរយៈពេលស្តុកទុកពី ៥ថ្ងៃ ទៅ ៧ថ្ងៃ។

៣. <u>តម្លៃច្រកទ្វារ</u>

| ប្រភេទកុងតឺន័រ | តម្លៃបច្ចុប្បន្នក្នុង ១កុងតឺន័រ | តម្លៃអនុគ្រោះថ្មីក្នុង ១កុងតឺន័រ |
|---|---|---|
| កុងតឺន័រ ២០ហ្វីត | ៥ ដុល្លារអាមេរិក | ៣ ដុល្លារអាមេរិក |
| កុងតឺន័រ ៤០ហ្វីត | ៨ ដុល្លារអាមេរិក | ៥ ដុល្លារអាមេរិក |

*<u>បញ្ជាក់:</u>* តម្លៃខាងលើនេះបានគិតរួមបញ្ចូលអាករលើតម្លៃបន្ថែម ១០% រួចហើយ។

តារាងតម្លៃខាងលើនេះ នឹងត្រូវអនុវត្តចំពោះរាល់កុងតឺន័រដែលមានប្រតិបត្តិការលើកដាក់ និងឆ្លងកាត់ច្រកទ្វារ ក. ស. ភ. ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ នេះតទៅ។

អាស្រ័យហេតុនេះ សូមអតិថិជនទាំងអស់ជ្រាបជាដំណឹង និងចូលរួមសហការអនុវត្តឲ្យមានប្រសិទ្ធភាព។

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានអគ្គនាយក**

**ហ៊ី-ប៊ុនថាវី**

# KINGDOM OF CAMBODIA

## Nation Religion King

**Phnom Penh Autonomous Port**

Nº: ....078/19.........PPAP

PHNOM PENH, Date: March 29, 2019

# Announcement

**On**

**The Adjusted Tariff of Port's Services at Phnom Penh Autonomous Port**

**Phnom Penh Autonomous Port (PPAP)** would like to inform all valued customers that in order to contribute to the reduction of transportation and logistics cost with the purpose of facilitating the business and trade in Cambodia, PPAP has decided to adjust the tariff of PPAP's services as following:

1- **Stevedoring Charges ( the operation from ship to container yard and vice versa)**

| Types of Containers | Present Tariff per Container | Newly Discounted Tariff per Container |
|---|---|---|
| Empty Container 20' | USD 36 | USD 30 |
| Laden Container 20' | USD 65 | USD 56 |
| Empty Container 40' | USD 53 | USD 46 |
| Laden Container 40' | USD 99 | USD 85 |

*Note:* The tariff above is exclusive of Value Added Tax 10%.

2- The free storage period for export containers has been added from 5days to 7days.

3- **Gate Fee**

| Types of Containers | Present Tariff per Container | Newly Discounted Tariff per Container |
|---|---|---|
| Container 20' | USD 5 | USD 3 |
| Container 40' | USD 8 | USD 5 |

*Note:* The tariff above is already inclusive of Value Added Tax 10%.

The tariff above shall be implemented for the operation of handling and movement of containers via PPAP from **the 1st of April, 2019 onwards.**

Please all valued customers kindly be informed and cooperate accordingly.

Yours Sincerely,

**Bavy Hei**
**Delegate of Royal Government**
**in Charge as Chairman and CEO**

Head Office: # 649, Preah Sisowath Quay, Sangkat Sras Chork, Khan Daun Penh, Phnom Penh Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh